ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤៥ អនក្រ.បក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានកិច្ចការរដ្ឋបាល
ចូល
លេខ ៣០៤១
ថ្ងៃទី ១៣..០៩..១២
ម៉ោង

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតប្រព័ន្ធស្បៀងបម្រុងកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស់ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៩/៨៦៦ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតក្រុមហ៊ុនគ្រឿនគ្រេង
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី៦១ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងបង្កើតប្រព័ន្ធស្បៀងបម្រុងកម្ពុជា ដែលសរសេរជាអក្សរកាត់ថា **ប.ស.ប.ក.** ដើម្បីជួយសង្គ្រោះប្រជាពលរដ្ឋរងគ្រោះដោយសារគ្រោះមហន្តរាយឬគ្រោះអាសន្ននានាឱ្យទាន់ពេលវេលា។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅ ៖

- គ្រប់គ្រងប្រព័ន្ធព័ត៌មានស្បៀងនិងគ្រាប់ពូជបម្រុង ស្ថានភាពសន្និធិស្បៀង គ្រាប់ពូជ និងធនធានហិរញ្ញវត្ថុរបស់ **ប.ស.ប.ក.**

- បង្កើតគណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា ហៅកាត់ថាគណៈកម្មាធិការ **ប.ស.ប.ក.**
- ដោះស្រាយការផ្គត់ផ្គង់ជាបន្ទាន់នូវស្បៀងដែលជាតម្រូវការចាំបាច់សម្រាប់ប្រជាពលរដ្ឋរងគ្រោះ ដោយសារគ្រោះមហន្តរាយឬគ្រោះអាសន្ននានា និង
- ដោះស្រាយការផ្គត់ផ្គង់ជាបន្ទាន់នូវគ្រាប់ពូជមានគុណភាពដល់ប្រជាកសិករដែលមានតម្រូវការចាំបាច់សម្រាប់ធានាការស្តារឡើងវិញនូវផ្ទៃដីដាំដុះដែលរងការខូចខាតដោយសារគ្រោះមហន្តរាយឬគ្រោះអាសន្ននានា។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់លើ ប្រជាពលរដ្ឋនិងប្រជាកសិកររងគ្រោះដោយសារគ្រោះមហន្តរាយឬគ្រោះអាសន្ននានាដែលត្រូវការជាបន្ទាន់នូវស្បៀងនិង/ឬគ្រាប់ពូជចាំបាច់ក្នុងការស្តារឡើងវិញនូវផ្ទៃដីដាំដំណាំស្រូវ បន្លែ និងដំណាំរួមផ្សំផ្សេងៗ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៤.-**

វាក្យសព្ទ "ប្រព័ន្ធស្បៀងបម្រុង" ដែលប្រើក្នុងអនុក្រឹត្យនេះសំដៅដល់ស្បៀងជាស្រូវ អង្ករ និងគ្រាប់ពូជមានគុណភាព រួមមានគ្រាប់ពូជដំណាំស្រូវ បន្លែ និងដំណាំរួមផ្សំផ្សេងៗទៀត ព្រមទាំងសាច់ប្រាក់បម្រុងទុក ដែលត្រូវផ្គត់ផ្គង់ឱ្យទាន់ពេលវេលាដល់ប្រជាពលរដ្ឋរងគ្រោះ ដោយសារគ្រោះមហន្តរាយឬគ្រោះអាសន្ននានា។

## ជំពូកទី២

## រចនាសម្ព័ន្ធនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការ ប.ស.ប.ក.

**មាត្រា ៥.-**

**ប.ស.ប.ក.** ស្ថិតនៅក្រោមការដឹកនាំនិងបញ្ជាផ្ទាល់របស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

គណៈកម្មាធិការ **ប.ស.ប.ក.** ត្រូវបានបង្កើតឡើងដើម្បីបំពេញមុខងារជាសេនាធិការផ្ទាល់របស់នាយករដ្ឋមន្ត្រី ក្នុងការគ្រប់គ្រងដំណើរការនិងការរៀបចំសេចក្តីព្រាងគោលនយោបាយនានាសម្រាប់ **ប.ស.ប.ក.**។

គណៈកម្មាធិការ **ប.ស.ប.ក.** មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| - តំណាងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | អនុប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| - តំណាងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ | សមាជិក |
| - តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| - តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| - តំណាងភាកបាទក្រហមកម្ពុជា | សមាជិក។ |

សមាសភាពជាក់ស្តែងត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

គណៈកម្មាធិការ **ប.ស.ប.គ.** មានលេខាធិការដ្ឋានមួយដែលស្ថិតនៅក្នុងអគ្គលេខាធិការដ្ឋានរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា ៦.-**

គណៈកម្មាធិការ **ប.ស.ប.គ.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម ៖

- គ្រប់គ្រងប្រព័ន្ធព័ត៌មានស្បៀងនិងគ្រាប់ពូជបម្រុង ស្ថានភាពសន្និធិស្បៀង គ្រាប់ពូជ និងធនធានហិរញ្ញវត្ថុរបស់ **ប.ស.ប.គ.**
- កំណត់បទដ្ឋានអនុវត្តការងារសម្រាប់គ្រប់គ្រងនិងសម្របសម្រួលការបំពេញតួនាទីនិងភារកិច្ចរបស់ស្ថាប័នពាក់ព័ន្ធ ទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិនៅក្នុង **ប.ស.ប.គ.**
- ពិនិត្យនិងវាយតម្លៃលើវិធានការផ្គត់ផ្គង់ស្បៀងនិងគ្រាប់ពូជបម្រុង ដែលបានឆ្លើយតបកន្លងមកទៅនឹងគ្រោះមហន្តរាយឬគ្រោះអាសន្ននានា ដើម្បីកែលម្អនិងបង្កើនប្រសិទ្ធភាពរបស់ **ប.ស.ប.គ.**
- ពិនិត្យតម្រូវការស្បៀងនិងគ្រាប់ពូជបម្រុងសម្រាប់បម្រើកិច្ចប្រតិបត្តិការសង្គ្រោះបន្ទាន់ ដោយផ្អែកលើដំណើរវិវត្តនៃស្ថានភាពសង្គមជាក់ស្តែង និងលទ្ធភាពធនធានរបស់ប្រទេស
- ត្រួតពិនិត្យនិងសម្រេចលើការបំពេញបន្ថែមសន្និធិស្បៀងនិងគ្រាប់ពូជបម្រុង ដើម្បីធានាគុណភាពតាមនិយាមបច្ចេកទេស
- រៀបចំរបាយការណ៍ប្រចាំឆ្នាំនិងរបាយការណ៍តាមការចាំបាច់នៃប្រតិបត្តិការសង្គ្រោះបន្ទាន់ និងផ្តល់យោបល់ជូននាយករដ្ឋមន្ត្រី
- រៀបចំសេចក្តីព្រាងគោលនយោបាយនិងយុទ្ធសាស្ត្រនៃ **ប.ស.ប.គ.** ជូននាយករដ្ឋមន្ត្រីដើម្បីពិនិត្យនិងសម្រេច
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំសម្រាប់ **ប.ស.ប.គ.**
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីនាយករដ្ឋមន្ត្រី។

**មាត្រា ៧.-**

សមាជិកគណៈកម្មាធិការ **ប.ស.ប.គ.** ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន។

ក្នុងករណីប្រធានអវត្តមាន អនុប្រធានឬសមាជិកដែលទទួលបានការផ្ទេរសិទ្ធិ ត្រូវកោះអញ្ជើញនិងដឹកនាំការប្រជុំរបស់គណៈកម្មាធិការ **ប.ស.ប.គ.**។

**មាត្រា ៨.-**

គណៈកម្មាធិការ **ប.ស.ប.គ.** ត្រូវរៀបចំកិច្ចប្រជុំសាមញ្ញមួយដងក្នុងមួយឆ្នាំ ដើម្បី៖

- ពិនិត្យនិងវាយតម្លៃលើការបញ្ចេញនិងការចែកចាយស្បៀងនិងគ្រាប់ពូជបម្រុង
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំសម្រាប់ **ប.ស.ប.គ.**

-ធ្វើរបាយការណ៍ស្តីពីប្រតិបត្តិការសង្គ្រោះបន្ទាន់ និង

-ដោះស្រាយបញ្ហាដែល **ប.ស.ប.ក.** បានជួបប្រទះចំពោះមុខ។

គណៈកម្មាធិការ **ប.ស.ប.ក.** ត្រូវរៀបចំកិច្ចប្រជុំសាមញ្ញនៅរៀងរាល់បីឆ្នាំម្តងដើម្បី៖

-ពិនិត្យវាយតម្លៃ កែលម្អ និងបង្កើនប្រសិទ្ធភាពរបស់ **ប.ស.ប.ក.** និង

-រៀបចំសេចក្តីព្រាងគោលនយោបាយនិងយុទ្ធសាស្ត្រនៃ **ប.ស.ប.ក.** ជូននាយករដ្ឋមន្ត្រីពិនិត្យ និងសម្រេច។

គណៈកម្មាធិការ **ប.ស.ប.ក.** អាចរៀបចំកិច្ចប្រជុំវិសាមញ្ញរបស់ខ្លួនតាមការចាំបាច់ ដើម្បីឆ្លើយតបជាបន្ទាន់ទៅនឹងគ្រោះមហន្តរាយឬគ្រោះអាសន្ននានាដែលបានកើតឡើង។

**មាត្រា ៩.-**

គណៈកម្មាធិការ **ប.ស.ប.ក.** មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៣

## គោលការណ៍គ្រប់គ្រងនិងចាត់ចែងសន្និធិស្បៀងនិងគ្រាប់ពូជបម្រុងដំបូង

### ផ្នែកទី១

### គោលការណ៍គ្រប់គ្រង

**មាត្រា ១០.-**

**ប.ស.ប.ក.** ត្រូវមានសន្និធិស្បៀងបម្រុងដំបូងសមមូលនឹងអង្ករសរុបចំនួន១៦ ០០០(ដប់ប្រាំមួយពាន់)តោន ដែលត្រូវកំណត់ដូចខាងក្រោម៖

-សន្និធិស្បៀងបម្រុងជាអង្ករសរុបចំនួន១០ ០០០(ដប់ពាន់)តោន ត្រូវជា៦២,៥%នៃសន្និធិស្បៀងបម្រុងដំបូង

-សន្និធិស្បៀងបម្រុងជាសាច់ប្រាក់សរុបសមមូលនឹងអង្ករចំនួន៦ ០០០(ប្រាំមួយពាន់)តោន ត្រូវជា៣៧,៥%នៃសន្និធិស្បៀងបម្រុងដំបូង។

ក្នុងករណីចាំបាច់ សន្និធិស្បៀងបម្រុងដំបូងដែលបានកំណត់ខាងលើ អាចកែសម្រួលដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់គណៈកម្មាធិការ **ប.ស.ប.ក.**។

**មាត្រា ១១.-**

សន្និធិស្បៀងបម្រុងដំបូងជាអង្ករចំនួន១០ ០០០(ដប់ពាន់)តោន ត្រូវគ្រប់គ្រងដោយក្រុមហ៊ុនហ្គ្រីនត្រេដ ដែលជាសេនាធិការឱ្យក្រសួងពាណិជ្ជកម្ម ដោយក្នុងនោះសន្និធិស្បៀងបម្រុងជាអង្ករចំនួន៧ ០០០(ប្រាំពីរពាន់)តោន ត្រូវគ្រប់គ្រងដោយផ្ទាល់ និង៣ ០០០(បីពាន់)តោនផ្សេងទៀតត្រូវគ្រប់គ្រងដោយក្រុមហ៊ុនឯកជន តាមរយៈកិច្ចសន្យាសហការជាដៃគូ។ ក្រុមហ៊ុនហ្គ្រីនត្រេដត្រូវបានអនុញ្ញាតឱ្យរក្សាទុកសន្និធិស្បៀងបម្រុងជាស្រូវតាមបរិមាណសមមូលនឹងអង្ករដែលបានកំណត់។

សន្និធិស្បៀងបម្រុងដំបូងជាអង្ករ ត្រូវរក្សាទុកយ៉ាងហ្មត់ចត់ ដោយអនុលោមតាមលក្ខខណ្ឌបច្ចេកទេស នៃការរក្សាទុក។

សន្និធិស្បៀងបម្រុងដំបូងជាសាច់ប្រាក់សមមូលនឹងអង្ករចំនួន៦ ០០០(ប្រាំមួយពាន់)តោន ត្រូវគ្រប់គ្រង ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា ១២.-**

**ម.ស.ម.ក.** ត្រូវមានសន្និធិគ្រាប់ពូជបម្រុងដំបូង តាមការកំណត់ដូចខាងក្រោម៖

- សន្និធិគ្រាប់ពូជស្រូវស្រាលមិនប្រកាន់រដូវសរុបសមមូលចំនួន៣ ០០០(បីពាន់)តោន ដែលក្នុង នោះ២ ០០០(ពីរពាន់)តោន ជាគ្រាប់ពូជ និង១ ០០០(មួយពាន់)តោនផ្សេងទៀតជាសាច់ប្រាក់
- សន្និធិគ្រាប់ពូជបន្លែនិងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗទៀតសរុបសមមូលចំនួន៥០(ហាសិប) តោន ដែលក្នុងនោះ២៥(ម្ភៃប្រាំ)តោនជាគ្រាប់ពូជ និង២៥(ម្ភៃប្រាំ)តោនផ្សេងទៀតជាសាច់ប្រាក់។

ក្នុងករណីចាំបាច់ សន្និធិគ្រាប់ពូជបម្រុងដំបូងដែលបានកំណត់ខាងលើ អាចកែសម្រួលដោយ នាយករដ្ឋមន្ត្រី តាមសំណើរបស់គណៈកម្មាធិការ **ម.ស.ម.ក.**។

**មាត្រា ១៣.-**

សន្និធិគ្រាប់ពូជស្រូវស្រាលបម្រុងដំបូងចំនួន២ ០០០(ពីរពាន់)តោន និងសន្និធិគ្រាប់ពូជបន្លែនិង គ្រាប់ពូជដំណាំរួមផ្សំផ្សេងៗដំបូងចំនួន២៥(ម្ភៃប្រាំ)តោន ត្រូវគ្រប់គ្រងដោយអគ្គនាយកដ្ឋានកសិកម្មដែល ជាសេនាធិការឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយផ្ទាល់ឬតាមរយៈកសិដ្ឋាន ស្ថានីយ ក្រុមហ៊ុនឯកជន និងសហគមន៍កសិករដែលផលិតគ្រាប់ពូជស្រូវ គ្រាប់ពូជបន្លែ និងគ្រាប់ពូជដំណាំរួមផ្សំ ផ្សេងៗ។

សន្និធិគ្រាប់ពូជស្រូវបម្រុងដំបូងជាសាច់ប្រាក់សមមូលនឹងគ្រាប់ពូជចំនួន១ ០០០(មួយពាន់)តោន និង សន្និធិគ្រាប់ពូជបន្លែនិងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗបម្រុងដំបូង ជាសាច់ប្រាក់សមមូលនឹងគ្រាប់ពូជចំនួន ២៥(ម្ភៃប្រាំ)តោន ត្រូវគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គ្រាប់ពូជស្រូវស្រាល គ្រាប់ពូជបន្លែ និងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗទៀត ដែលរក្សាទុកជាសន្និធិ គ្រាប់ពូជបម្រុងរបស់ **ម.ស.ម.ក.** ត្រូវផលិតនិងរក្សាទុកយ៉ាងហ្មត់ចត់ ដោយអនុលោមតាមលក្ខខណ្ឌ បច្ចេកទេសនៃការផលិតនិងការរក្សាទុកគ្រាប់ពូជ។

## ផ្នែកទី២
## គោលការណ៍ចាត់ចែង

**មាត្រា ១៤.-**

ក្នុងករណីមានតម្រូវការសង្គ្រោះបន្ទាន់ដោយសារគ្រោះមហន្តរាយឬគ្រោះអាសន្ននានា នាយករដ្ឋមន្ត្រី មានសិទ្ធិសម្រេចចាត់ចែងសន្និធិស្បៀងនិងគ្រាប់ពូជបម្រុង ជារូបវន្តឬជាសាច់ប្រាក់ ដើម្បីជួយដល់ ប្រជាពលរដ្ឋរងគ្រោះ តាមតម្រូវការចាំបាច់និងបន្ទាន់ដូចខាងក្រោម៖

-តម្រូវការស្បៀងជាអង្ករលើសពី១ ០០០(មួយពាន់)តោន

-តម្រូវការគ្រាប់ពូជស្រូវលើសពី១០០(មួយរយ)តោន

-តម្រូវការគ្រាប់ពូជបន្លែនិងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗទៀត លើសពី១០(ដប់)តោន

-តម្រូវការដកប្រាក់ពីក្នុងគណនីតម្កល់មូលនិធិប្រាក់បម្រុង ដើម្បីទិញស្បៀងបន្ថែមលើសពី១ ០០០(មួយពាន់)តោន គ្រាប់ពូជស្រូវបន្ថែមលើសពី១០០(មួយរយ)តោន និងគ្រាប់ពូជបន្លែនិងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗទៀតបន្ថែមលើសពី១០(ដប់)តោន ។

**មាត្រា ១៥.-**

ក្នុងករណីមានតម្រូវការសង្គ្រោះបន្ទាន់ដោយសារគ្រោះមហន្តរាយឬគ្រោះអាសន្ននានា គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានសិទ្ធិសម្រេចចាត់ចែងសន្និធិស្បៀងនិងគ្រាប់ពូជបម្រុង ដើម្បីចែកចាយជូនប្រជាពលរដ្ឋរងគ្រោះ តាមតម្រូវការចាំបាច់និងបន្ទាន់ដូចខាងក្រោម៖

-តម្រូវការស្បៀងជាអង្ករតិចជាងឬស្មើ១ ០០០(មួយពាន់)តោន

-តម្រូវការគ្រាប់ពូជស្រូវក្នុងចន្លោះពី៣០(សាមសិប)តោន ទៅ១០០(មួយរយ)តោន

-តម្រូវការគ្រាប់ពូជបន្លែនិងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗទៀត ក្នុងចន្លោះពី ១(មួយ)តោន ទៅ១០(ដប់)តោន។

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ អាចអនុវត្តសិទ្ធិសម្រេចចាត់ចែងសន្និធិស្បៀងនិងគ្រាប់ពូជបម្រុងនេះ បន្ទាប់ពីបានជូនដំណឹងជាមុនដល់នាយករដ្ឋមន្ត្រីនិងគណៈកម្មាធិការ **ប.ស.ប.ក.**។

**មាត្រា ១៦.-**

ក្នុងករណីមានតម្រូវការសង្គ្រោះបន្ទាន់ដោយសារគ្រោះមហន្តរាយឬគ្រោះអាសន្ននានា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិសម្រេចចាត់ចែងសន្និធិគ្រាប់ពូជបម្រុង ដើម្បីចែកចាយជូនប្រជាពលរដ្ឋរងគ្រោះ តាមតម្រូវការចាំបាច់និងបន្ទាន់ដូចខាងក្រោម៖

-តម្រូវការគ្រាប់ពូជស្រូវតិចជាង៣០(សាមសិប)តោន

-តម្រូវការគ្រាប់ពូជបន្លែនិងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗទៀតតិចជាង ១(មួយ)តោន។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចអនុវត្តសិទ្ធិសម្រេចចាត់ចែងសន្និធិគ្រាប់ពូជបម្រុងនេះ បន្ទាប់ពីបានជូនដំណឹងជាមុនដល់នាយករដ្ឋមន្ត្រី គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និង គណៈកម្មាធិការ **ប.ស.ប.ក.**។

**មាត្រា ១៧.-**

ក្នុងករណីមានតម្រូវការសង្គ្រោះបន្ទាន់ដោយសារគ្រោះមហន្តរាយឬគ្រោះអាសន្ននានា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិសម្រេចដកប្រាក់ចេញពីគណនីតម្កល់មូលនិធិប្រាក់បម្រុង ដើម្បីទិញបន្ថែមសន្និធិស្បៀងនិងគ្រាប់ពូជបម្រុងតាមតម្រូវការចាំបាច់និងបន្ទាន់ដូចខាងក្រោម៖

-តម្រូវការទិញស្បៀងជាអង្ករតិចជាងឬស្មើ១ ០០០(មួយពាន់)តោន

-តម្រូវការទិញគ្រាប់ពូជស្រូវតិចជាងឬស្មើ១០០(មួយរយ)តោន

-តម្រូវការទិញគ្រាប់ពូជបន្ថែនិងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗទៀតតិចជាងឬស្មើ១០(ដប់)តោន

-តម្រូវការចំណាយផ្សេងៗនៅក្នុងក្របខ័ណ្ឌ ម.ស.ម.គ.។

**មាត្រា ១៨.-**

ក្នុងករណីមានតម្រូវការសង្គ្រោះបន្ទាន់ដោយសារគ្រោះមហន្តរាយឬគ្រោះអាសន្ននានា គ្រាប់ពូជបម្រុងមានគុណភាព ត្រូវចែកចាយដោយឥតគិតថ្លៃជូនដល់ប្រជាកសិកររងគ្រោះ ដោយអនុលោមតាមបទបញ្ជារបស់នាយករដ្ឋមន្ត្រី។

ក្នុងករណីគ្មានបទបញ្ជាខាងលើ គ្រាប់ពូជបម្រុងមានគុណភាព ត្រូវលក់ដោយការបញ្ចុះថ្លៃ៥០% (ហាសិបភាគរយ)ធៀបនឹងតម្លៃទីផ្សារ តាមរយៈឧបត្ថម្ភធនជូនប្រជាកសិកររងគ្រោះ។ ចំណូលដែលប្រមូលបានពីការលក់គ្រាប់ពូជនេះ ត្រូវផ្ទេរដោយស្វ័យប្រវត្តិចូលក្នុងគណនីតម្កល់មូលនិធិប្រាក់បម្រុង។

**មាត្រា ១៩.-**

គណៈកម្មាធិការ ម.ស.ម.គ. ត្រូតពិនិត្យលើការបំពេញបន្ថែមសន្និធិស្បៀងនិងគ្រាប់ពូជបម្រុង នៅពេលដែលគុណភាពធ្លាក់ចុះទាបជាងនិយាមបច្ចេកទេស។ សន្និធិស្បៀងនិងគ្រាប់ពូជបម្រុងដែលត្រូវបានពិនិត្យឃើញថាថយឬបាត់បង់គុណភាព ត្រូវបញ្ចេញលក់ជាបន្ទាន់និងបំពេញបង្គ្រប់ជាថ្មី។

ចំណូលដែលប្រមូលបានពីការលក់ខាងលើ ត្រូវផ្ទេរដោយស្វ័យប្រវត្តិចូលក្នុងគណនីតម្កល់មូលនិធិប្រាក់បម្រុង។

**មាត្រា ២០.-**

ធនធានហិរញ្ញវត្ថុដែលផ្តល់ដោយបណ្តាដៃគូអភិវឌ្ឍ (រួមទាំងទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ) សង្គមស៊ីវិល វិស័យឯកជន និងសប្បុរសជនទាំងអស់ សម្រាប់ដំណើរការនៃ ម.ស.ម.គ. ត្រូវផ្ទេរដោយស្វ័យប្រវត្តិចូលក្នុងគណនីតម្កល់មូលនិធិប្រាក់បម្រុង។

## ជំពូកទី៤

## តួនាទីនិងភារកិច្ចរបស់ក្រសួង ស្ថាប័នអនុវត្តក្នុង ម.ស.ម.គ.

**មាត្រា ២១.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងពាណិជ្ជកម្ម ក្រសួងមហាផ្ទៃ គឺជាស្ថាប័នអនុវត្តនៅក្នុង ម.ស.ម.គ. ដែលត្រូវបំពេញតួនាទីនិងភារកិច្ចតាមសមត្ថកិច្ចរៀងៗខ្លួន។

**មាត្រា ២២.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវប្រគល់តួនាទីជាអង្គភាពអនុវត្តក្នុង ម.ស.ម.គ. ដល់មន្ត្រីជាន់ខ្ពស់មួយរូប និងអង្គភាពពាក់ព័ន្ធក្រោមឱវាទរបស់ខ្លួនដើម្បីបំពេញភារកិច្ចបន្ថែមដូចខាងក្រោម៖

- គ្រប់គ្រងគណនីតម្កល់មូលនិធិប្រាក់បម្រុងសម្រាប់កិច្ចលទ្ធកម្ម ការថែរក្សា ការស្តុកទុក ការដឹកជញ្ជូន និងប្រតិបត្តិការផ្សេងៗពាក់ព័ន្ធនឹងស្បៀងនិងគ្រាប់ពូជបម្រុងរបស់ ម.ស.ម.គ.

- តាមដាននិងត្រួតពិនិត្យការប្រើប្រាស់មូលនិធិប្រាក់បម្រុងក្នុងការទិញស្បៀងនិងគ្រាប់ពូជបម្រុង សម្រាប់ **ប.ស.ប.គ.**
- រៀបចំបម្រុងទុកថវិកាសម្រាប់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងពាណិជ្ជកម្ម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការថែរក្សាស្បៀងនិងគ្រាប់ពូជ ការផលិតគ្រាប់ពូជ ប្រតិបត្តិការសង្គ្រោះបន្ទាន់ និងប្រតិបត្តិការផ្សេងៗ ដែលទាក់ទងនឹង **ប.ស.ប.គ.**
- រៀបចំបូកសរុបថវិកាប្រចាំឆ្នាំរបស់ **ប.ស.ប.គ.** ដែលស្នើឡើងដោយក្រសួងពាណិជ្ជកម្មសម្រាប់ស្បៀង និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់គ្រាប់ពូជ ដើម្បីស្នើសុំការអនុម័ត ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីហិរញ្ញវត្ថុជាធរមាន
- គ្រប់គ្រងថវិកាទាំងអស់របស់ **ប.ស.ប.គ.**
- រៀបចំរបាយការណ៍ប្រចាំត្រីមាសនិងតាមការចាំបាច់ ជូននាយករដ្ឋមន្ត្រី និងជូនដំណឹងដល់ស្ថាប័នពាក់ព័ន្ធទាំងអស់ អំពីសភាពការណ៍ទូទៅរបស់ **ប.ស.ប.គ.**
- រៀបចំកិច្ចប្រជុំរបស់គណៈកម្មាធិការ **ប.ស.ប.គ.**។

**មាត្រា ២៣.-**

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវប្រគល់តួនាទីជាអង្គភាពអនុវត្តក្នុង **ប.ស.ប.គ.** ដល់អគ្គលេខាធិការដ្ឋានរបស់ខ្លួន ដែលមានអគ្គលេខាធិការរងមួយរូបទទួលបន្ទុក ដើម្បីបំពេញភារកិច្ចបន្ថែមដូចខាងក្រោម៖

- គ្រប់គ្រងទិន្នន័យស្តីពីការប៉ាន់ប្រមាណនូវហានិភ័យនៃគ្រោះមហន្តរាយឬគ្រោះអាសន្ននានា
- រៀបចំនិងធ្វើការប៉ាន់ប្រមាណអំពីតម្រូវការស្បៀងនិងជួយធ្វើការប៉ាន់ប្រមាណគ្រាប់ពូជបន្ទាន់ នៅពេលមានគ្រោះមហន្តរាយឬគ្រោះអាសន្ននានា
- សម្របសម្រួលជាមួយស្ថាប័ននិងដៃគូអភិវឌ្ឍនានា ដើម្បីចែករំលែកព័ត៌មានស្តីពីតម្រូវការស្បៀងនិងគ្រាប់ពូជបន្ថែម
- រៀបចំរបាយការណ៍អំពីតម្រូវការស្បៀងបន្ទាន់ ជូននាយករដ្ឋមន្ត្រីដើម្បីជ្រាប ឬចាត់វិធានការចាំបាច់សម្រាប់ស្ថាប័នពាក់ព័ន្ធអនុវត្ត
- សម្របសម្រួលក្នុងការឆ្លើយតប នៅពេលមានគ្រោះមហន្តរាយឬគ្រោះអាសន្ននានាកើតឡើង
- សម្របសម្រួលក្នុងការកំណត់រកប្រជាពលរដ្ឋគោលដៅ ដែលទទួលរងផលប៉ះពាល់ដោយសារគ្រោះមហន្តរាយឬគ្រោះអាសន្ននានា
- សម្របសម្រួលការដឹកជញ្ជូននិងការដឹកនាំកិច្ចប្រតិបត្តិការចែកចាយស្បៀងជូនដល់ប្រជាពលរដ្ឋរងគ្រោះ

- សម្រួលការដឹកជញ្ជូន ការចែកចាយគ្រាប់ពូជ និងការលក់គ្រាប់ពូជតាមរយៈឧបត្ថម្ភធន ដល់ប្រជាកសិកររងគ្រោះ
- ប្រមូលនិងផ្ទេរប្រាក់ដែលទទួលបានពីការលក់គ្រាប់ពូជតាមរយៈឧបត្ថម្ភធន ទៅក្នុងគណនីតម្កល់មូលនិធិប្រាក់បម្រុង
- ប្រមូល ត្រួតពិនិត្យ និងគ្រប់គ្រងប្រព័ន្ធព័ត៌មានស្បៀងនិងគ្រាប់ពូជបម្រុងរបស់ **ម.ស.ម.ក.**
- ត្រួតពិនិត្យភស្តុភារ ស្បៀង និងគ្រាប់ពូជរបស់ **ម.ស.ម.ក.**។

**មាត្រា ២៤.-**

ទីស្តីការគណៈរដ្ឋមន្ត្រី បំពេញតួនាទីជាអង្គភាពអនុវត្តក្នុង **ម.ស.ម.ក.** តាមរយៈភារកិច្ចដូចខាងក្រោម៖

- ចូលរួមផ្សព្វផ្សាយសភាពការណ៍ពាក់ព័ន្ធនឹងគ្រោះមហន្តរាយឬគ្រោះអាសន្ននានា
- ចូលរួមកៀរគរកជំនួយពីគ្រប់មជ្ឈដ្ឋាន
- សម្របសម្រួលការងាររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ។

**មាត្រា ២៥.-**

ក្រសួងមហាផ្ទៃ ចូលរួមបំពេញតួនាទីជាអង្គភាពអនុវត្តក្នុង **ម.ស.ម.ក.** តាមរយៈរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដោយបំពេញភារកិច្ចដូចខាងក្រោម៖

- សម្រួលការផ្តល់ព័ត៌មានស្តីពីស្ថានភាពទូទៅនៃតំបន់ដែលទទួលរងគ្រោះ ដោយសារគ្រោះមហន្តរាយឬគ្រោះអាសន្ននានា
- សម្រួលការប្រមូលទិន្នន័យនិងការប៉ាន់ប្រមាណអំពីហានិភ័យដែលកើតឡើងដោយសារគ្រោះមហន្តរាយឬគ្រោះអាសន្ននានា
- សម្រួលការប្រមូលទិន្នន័យនិងការប៉ាន់ប្រមាណអំពីតម្រូវការស្បៀងនិងគ្រាប់ពូជ
- ផ្តល់កិច្ចសហការដើម្បីកំណត់ប្រជាពលរដ្ឋគោលដៅ ដែលត្រូវទទួលការចែកចាយស្បៀងនិងគ្រាប់ពូជ
- ផ្តល់កិច្ចសហការដើម្បីធ្វើការចែកចាយស្បៀងនិងគ្រាប់ពូជឬការលក់គ្រាប់ពូជតាមរយៈឧបត្ថម្ភធន
- ផ្តល់ការគាំទ្រនិងសហការត្រួតពិនិត្យលើការចែកចាយស្បៀងនិងគ្រាប់ពូជ។

**មាត្រា ២៦.-**

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ បំពេញតួនាទីជាអង្គភាពអនុវត្តក្នុង **ម.ស.ម.ក.** តាមរយៈភារកិច្ចដូចខាងក្រោម៖

- រៀបចំនិងផ្សព្វផ្សាយឱ្យបានទៀងទាត់នូវព្រឹត្តិបត្រប្រចាំត្រីមាសស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ

- រៀបចំនិងផ្សព្វផ្សាយឱ្យបានទៀងទាត់នូវរបាយការណ៍តាមដាននិងវាយតម្លៃស្តីពីស្ថានភាពសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ
- ផ្តល់ព័ត៌មានស្តីពីស្ថានភាពសន្តិសុខស្បៀងនិងអាហារូបត្ថម្ភដល់ស្ថាប័នពាក់ព័ន្ធរបស់ **ប.ស.ប.ភ.** ដោយអនុលោមតាមអាណត្តិការងាររបស់ខ្លួន
- ផ្តល់ការគាំទ្រនិងសម្របសម្រួលក្នុងការតាមដាននិងវាយតម្លៃ ដើម្បីធ្វើឱ្យ **ប.ស.ប.ភ.** ធានានូវតម្លាភាពនិងគណនេយ្យភាព។

**មាត្រា ២៧.-**

ក្រសួងពាណិជ្ជកម្ម ត្រូវប្រគល់តួនាទីជាអង្គភាពអនុវត្តក្នុង **ប.ស.ប.ភ.** ដល់ក្រុមហ៊ុនហ្គ្រីនត្រេដ ដើម្បីបំពេញភារកិច្ចបន្ថែមដូចខាងក្រោម ៖

- រៀបចំកិច្ចលទ្ធកម្មសន្និធិស្បៀងបម្រុងជាអង្ករបស់ **ប.ស.ប.ភ.**
- ជ្រើសរើសនិងចុះកិច្ចសន្យាសហការជាដៃគូជាមួយក្រុមហ៊ុនឯកជន នៅក្នុង**ប.ស.ប.ភ.** ដោយធានាបាននូវបរិមាណ គុណភាព និងការដឹកជញ្ជូនស្បៀងទាន់ពេលវេលា ទៅកាន់គោលដៅចែកចាយ
- ធានាដឹកជញ្ជូនស្បៀងបម្រុងទាន់ពេលវេលាទៅកាន់គោលដៅចែកចាយនៅក្នុង **ប.ស.ប.ភ.**
- គ្រប់គ្រងបញ្ជីសារពើភណ្ឌនៃសន្និធិស្បៀងបម្រុងទាំងអស់ ដែលមាននៅក្នុងឃ្លាំងផ្ទាល់របស់ក្រុមហ៊ុនហ្គ្រីនត្រេដនិងឃ្លាំងរបស់ក្រុមហ៊ុនឯកជនជាដៃគូ
- គ្រប់គ្រងនិងត្រួតពិនិត្យសន្និធិស្បៀងបម្រុង ដើម្បីធានាបរិមាណនិងគុណភាព
- រៀបចំសំណើផែនការថវិកាប្រចាំឆ្នាំ សម្រាប់កិច្ចលទ្ធកម្ម ការថែរក្សា ការគ្រប់គ្រង ការដឹកជញ្ជូន និងប្រតិបត្តិការផ្សេងៗពាក់ព័ន្ធនឹងស្បៀងបម្រុងរបស់ក្រុមហ៊ុនហ្គ្រីនត្រេដ នៅក្នុង **ប.ស.ប.ភ.**
- រៀបចំរបាយការណ៍ប្រចាំខែនិងតាមការចាំបាច់ ស្តីពីស្ថានភាពសន្និធិស្បៀងបម្រុងដែលគ្រប់គ្រងដោយផ្ទាល់ និងតាមរយៈកិច្ចសន្យាសហការជាដៃគូជាមួយក្រុមហ៊ុនឯកជននៅក្នុង **ប.ស.ប.ភ.** ដោយបញ្ជាក់ច្បាស់លាស់អំពីបរិមាណនិងគុណភាព ជូនគណៈកម្មាធិការ **ប.ស.ប.ភ.**។

**មាត្រា ២៨.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវប្រគល់តួនាទីជាអង្គភាពអនុវត្តក្នុង **ប.ស.ប.ភ.** ដល់អគ្គនាយកដ្ឋានកសិកម្ម ដើម្បីបំពេញភារកិច្ចបន្ថែមដូចខាងក្រោម ៖

- ធ្វើការប៉ាន់ប្រមាណអំពីការខូចខាតគ្រប់មុខដំណាំនិងតម្រូវការគ្រាប់ពូជបន្ទាន់
- រៀបចំកិច្ចលទ្ធកម្ម គ្រប់គ្រងការផលិត និងការថែរក្សាជារួមនូវគ្រាប់ពូជស្រូវបម្រុង គ្រាប់ពូជបន្លែ និងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗទៀតដែលមានគុណភាព

- ជ្រើសរើសនិងចុះកិច្ចសន្យាសហការជាដៃគូជាមួយក្រុមហ៊ុនឯកជននិងសហគមន៍កសិករ ដែលផលិតគ្រាប់ពូជស្រូវ គ្រាប់ពូជបន្លែ និងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗនៅក្នុង **ប.ស.ប.ក.** ដោយធានាបាននូវបរិមាណ គុណភាព និងការដឹកជញ្ជូនគ្រាប់ពូជទាន់ពេលវេលា ទៅកាន់គោលដៅចែកចាយ
- ធានាដឹកជញ្ជូនគ្រាប់ពូជបម្រុងទាន់ពេលវេលាទៅកាន់គោលដៅចែកចាយ នៅក្នុង **ប.ស.ប.ក.**
- គ្រប់គ្រងបញ្ជីសារពើភណ្ឌនៃសន្និធិគ្រាប់ពូជបម្រុង នៅក្នុងឃ្លាំងស្តុករបស់អគ្គនាយកដ្ឋានកសិកម្ម និងឃ្លាំងស្តុកគ្រាប់ពូជរបស់ក្រុមហ៊ុនឯកជន និងសហគមន៍កសិករ ដែលផលិតគ្រាប់ពូជជាដៃគូ
- គ្រប់គ្រងនិងត្រួតពិនិត្យសន្និធិគ្រាប់ពូជបម្រុង ដើម្បីធានាបរិមាណនិងគុណភាព
- រៀបចំសំណើផែនការថវិកាប្រចាំឆ្នាំ សម្រាប់កិច្ចលទ្ធកម្ម ការផលិត ការថែរក្សា ការគ្រប់គ្រង ការដឹកជញ្ជូន និងប្រតិបត្តិការផ្សេងៗពាក់ព័ន្ធនឹងគ្រាប់ពូជបម្រុងរបស់អគ្គនាយកដ្ឋានកសិកម្ម នៅក្នុង **ប.ស.ប.ក.**
- រៀបចំរបាយការណ៍ប្រចាំខែនិងតាមការចាំបាច់ ស្តីពីស្ថានភាពសន្និធិគ្រាប់ពូជបម្រុងរបស់អគ្គនាយកដ្ឋានកសិកម្មនៅក្នុង **ប.ស.ប.ក.** ដោយបញ្ជាក់យ៉ាងច្បាស់លាស់អំពីបរិមាណ និងគុណភាព ជូនគណៈកម្មាធិការ **ប.ស.ប.ក.**។

**មាត្រា ២៩.-**

កាកបាទក្រហមកម្ពុជា បណ្តាដៃគូអភិវឌ្ឍ (រួមទាំងទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ) សង្គមស៊ីវិល វិស័យឯកជន និងសប្បុរសជន ត្រូវបានលើកទឹកចិត្តឱ្យចូលរួមគាំទ្រដល់ដំណើរការរបស់ **ប.ស.ប.ក.** ដោយផ្តែកលើកិច្ចសហការនិងសម្របសម្រួលជាមួយគណៈកម្មាធិការ **ប.ស.ប.ក.** តាមរយៈសកម្មភាពជាអាទិភាព ដូចខាងក្រោម៖

- ការចែករំលែកព័ត៌មានស្តីពីតម្រូវការស្បៀងនិងគ្រាប់ពូជ
- ការកំណត់ប្រជាពលរដ្ឋគោលដៅដែលត្រូវទទួលការចែកចាយស្បៀងនិងគ្រាប់ពូជ
- ការផ្តល់កិច្ចគាំទ្រដល់ការចែកចាយស្បៀងនិងគ្រាប់ពូជដល់ប្រជាពលរដ្ឋរងគ្រោះដោយសារគ្រោះមហន្តរាយឬគ្រោះអាសន្ននានា
- ការផ្តល់កិច្ចគាំទ្រផ្នែកបច្ចេកទេសនិងថវិកាសម្រាប់គាំទ្រដល់ការប្រមូលទិន្នន័យ ការប៉ាន់ប្រមាណអំពីតម្រូវការស្បៀងនិងគ្រាប់ពូជបន្ទាន់
- ការចែករំលែកចំណេះដឹងនិងបទពិសោធពាក់ព័ន្ធនឹងប្រតិបត្តិការសង្គ្រោះបន្ទាន់ នៅពេលមានគ្រោះមហន្តរាយឬគ្រោះអាសន្ននានា
- ការផ្តល់កិច្ចគាំទ្រផ្នែកបច្ចេកទេសនិងថវិកាសម្រាប់គាំទ្រដល់សកម្មភាពពាក់ព័ន្ធនឹងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ

- ការផ្តល់កិច្ចគាំទ្រផ្នែកបច្ចេកទេសនិងថវិកាដល់ស្ថាប័នពាក់ព័ន្ធរបស់ ម.ស.ម.គ. សម្រាប់ការពង្រឹងសមត្ថភាពធនធានមនុស្សនិងស្ថាប័ន ព្រមទាំងប្រតិបត្តិការនានា ដែលទាក់ទងទៅនឹងដំណើរការរបស់ ម.ស.ម.គ.។

## ជំពូកទី៥

## ប្រភពធនធាន

**មាត្រា ៣០.-**

ម.ស.ម.គ. មានថវិកាដោយឡែកដែលជាកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ម.ស.ម.គ. មានប្រភពធនធានមកពីថវិកាជាតិ បណ្តាដៃគូអភិវឌ្ឍ (រួមទាំងទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ) សង្គមស៊ីវិល វិស័យឯកជននិងសប្បុរសជននានា។

**មាត្រា ៣១.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំថវិកាសម្រាប់ដំណើរការ ម.ស.ម.គ. តាមការកំណត់ដូចខាងក្រោម៖

- ធ្វើកិច្ចលទ្ធកម្មសម្រាប់ការទិញអង្ករ ដើម្បីរក្សាទុកជាសន្និធិស្បៀងបម្រុងជាប្រចាំចំនួន ១០ ០០០(ដប់ពាន់)តោន
- ផលិតគ្រាប់ពូជបម្រុងនិងធ្វើកិច្ចលទ្ធកម្មសម្រាប់ការទិញគ្រាប់ពូជបម្រុងជាប្រចាំ ដូចជាគ្រាប់ពូជស្រូវស្រាលមិនប្រកាន់រដូវ ចំនួន២ ០០០(ពីរពាន់)តោន គ្រាប់ពូជបន្លែនិងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗទៀត ចំនួន២៥(ម្ភៃប្រាំ)តោន
- រក្សាទុកមូលនិធិសាច់ប្រាក់បម្រុង ដែលមានតម្លៃសមមូលនឹងអង្ករចំនួន៦ ០០០(ប្រាំមួយពាន់)តោន គ្រាប់ពូជស្រូវស្រាលមិនប្រកាន់រដូវចំនួន ១ ០០០(មួយពាន់)តោន ព្រមទាំងគ្រាប់ពូជបន្លែនិងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗទៀតចំនួន២៥ (ម្ភៃប្រាំ) តោន
- ចំណាយប្រតិបត្តិការផ្សេងៗរបស់ ម.ស.ម.គ. ដែលមានជាអាទិ៍ ចំណាយលើការគ្រប់គ្រងនិងការថែរក្សាសន្និធិ ការបំពេញបន្ថែមសន្និធិ ការជួលឃ្លាំង និងប្រតិបត្តិការចែកចាយស្បៀងនិងគ្រាប់ពូជបម្រុង។

**មាត្រា ៣២.-**

គណនីតម្កល់មូលនិធិប្រាក់បម្រុងត្រូវគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

រាល់ចំណូលនិងចំណាយដែលទាក់ទងនឹងដំណើរការរបស់ ម.ស.ម.គ. ត្រូវអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា ៣៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីស្នើសុំចុះហត្ថលេខា

**រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

លេខ ៣១៣ ចល.កសក

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើមនិងបញ្ជូនមក ៖

-ឯកឧត្តមថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

« ដើម្បីជូនជ្រាប »

-ឯកឧត្តម លោកប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-លោកប្រធានមន្ទីរកសិកម្មរាជធានី ខេត្ត

« ដើម្បីអនុវត្ត »

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១២

ត.ក. រដ្ឋមន្ត្រី

អគ្គលេខាធិការ